# ជំងឺ COVID-19៖ សំណួរដែលសួរញឹកញាប់

## តើវ៉ាក់សាំងបង្ការជំងឺ COVID-19 មានសុវត្ថិភាព និងប្រសិទ្ធភាពដែរឬទេ ?

មាន។ វ៉ាក់សាំងបង្ការជំងឺ COVID-19 មានសុវត្ថិភាព ប្រសិទ្ធភាព និងជាវិធីមួយល្អបំផុតក្នុងការការពារខ្លួនអ្នក និងអ្នកដែលនៅជុំវិញអ្នកពីការធ្លាក់ខ្លួនឈឺដោយសារជំងឺ COVID-19។ Atrius Health ផ្តល់អនុសាសន៍យ៉ាងខ្លាំងដល់អ្នកដើម្បីទទួលវ៉ាក់សាំងបង្ការជំងឺ COVID-19 នៅពេលដែលមានវ៉ាក់សាំងសម្រាប់អ្នក។

## តើខ្ញុំដឹងដោយរបៀបណា អំពីពេលដែលខ្ញុំអាចចាក់វ៉ាក់សាំងបាន?

ក្រសួងសុខាភិបាលសាធារណៈប្រចាំរដ្ឋ Massachusett កំណត់ថា នរណាខ្លះដែលអាចចាក់វ៉ាក់សាំងបាន និងនៅពេលណា។ ដើម្បីរកឱ្យឃើញថា តើពេលណាអ្នកមានសិទ្ធិទទួលបាន សូមចូលទៅ គេហទំព័ររបស់ក្រសួងសុខាភិបាលសាធារណៈប្រចាំរដ្ឋ Massachusett។ អ្នកក៏អាចប្រើផងដែរនូវ ឧបករណ៍នេះ ដើម្បីរកឱ្យឃើញថា តើពេលណាអ្នកអាចចាក់វ៉ាក់សាំងបាន។

## តើលក្ខខណ្ឌវេជ្ជសាស្ត្រដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ដំណាក់កាលទី 2 មានអ្វីខ្លះ?

CDC បានកំណត់បញ្ជីនៃលក្ខខណ្ឌដែលបណ្តាលឱ្យបុគ្គលម្នាក់ៗមាន *ហានិភ័យខ្ពស់*នៃជំងឺធ្ងន់ធ្ងរពីជំងឺ COVID-19 ។ រដ្ឋ Massachusetts ក៏បានកំណត់អត្តសញ្ញាណជំងឺហឺតពីកម្រិតមធ្យមទៅធ្ងន់ធ្ងរផងដែរថា ជាលក្ខខណ្ឌវេជ្ជសាស្ត្រដែលមានសិទ្ធិទទួលបាន។ សូមកត់សម្គាល់ថា អ្នកមិនចាំបាច់ផ្តល់នូវសំណុំឯកសារជាលាយលក្ខណ៍អក្សរណាមួយពីអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់អ្នកដែលបញ្ជាក់អំពីស្ថានភាពវេជ្ជសាស្ត្របច្ចុប្បន្នរបស់អ្នកដើម្បីចាក់វ៉ាក់សាំងក្នុងដំណាក់កាលទី 2 ឡើយ។
ទីតាំងចាក់វ៉ាក់សាំងនឹងយកការបញ្ជាក់ផ្ទាល់ខ្លួនរបស់អ្នកធ្វើជាភស្តុតាងដែលអ្នកមានសិទ្ធិទទួលបាន ហើយនឹងកក់ទុកការណាត់ជួបរបស់អ្នក។

- ជំងឺមហារីក
- ជំងឺតម្រងនោមរ៉ាំរ៉ៃ
- COPD (ជំងឺស្ទះបំពង់សួតរ៉ាំរ៉ៃ)
- សហរោគសញ្ញាដែលធ្វើឱ្យចុះខ្សោយ
- ស្ថានភាពបេះដូង ដូចជាបេះដូងខ្សោយ ជំងឺសរសៃឈាមបេះដូង ឬសាច់ដុំបេះដូង
- ស្ថានភាពនៃការចុះខ្សោយប្រព័ន្ធភាពស៊ាំ(ប្រព័ន្ធភាពស៊ាំចុះខ្សោយ) ដោយសារការផ្លាស់ប្តូរសរីរាង្គរឹង*
- ជំងឺធាត់ និងជំងឺធាត់ខ្លាំង (សន្ទស្សន៍ម៉ាស់ រាងកាយ[BMI] ចំនួន 30 kg/m2 ឬខ្ពស់ជាងនេះ )
  - គណនា BMI របស់អ្នកនៅទីនេះ៖ កម្មវិធីគណនា BMI មនុស្សពេញវ័យ | CDC
- ការមានផ្ទៃពោះ**
- ជំងឺគោលិកាឈាមរាងកណ្តៀវ
- ការជក់បារី
- ជំងឺទឹកនោមផ្អែម ប្រភេទ 2
- ជំងឺហឺត (មធ្យមទៅធ្ងន់)

**សម្រាប់ក្រុមនេះ ដូសនេះមិនរួមបញ្ចូលបុគ្គលដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយដោយសារលក្ខខណ្ឌផ្សេងទៀតទេ ដូចជាការផ្សាំឈាម ឬការខួរឆ្អឹង ឬជំងឺអេដស៍(Human Immunodeficiency Virus, HIV)*

***ប្រសិនបើអ្នកមានផ្ទៃពោះ ឬកំពុងបំបៅកូនដោយទឹកដោះម្ដាយ ហើយមានសំណួរជុំវិញការទទួលវ៉ាក់សាំង ការពិភាក្សាជាមួយអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នកអាចនឹងជួយអ្នកធ្វើការសម្រេចចិត្តបានត្រឹមត្រូវ។*

## តើការបញ្ជាក់គឺជាអ្វី?

ដើម្បីទទួលវ៉ាក់សាំងនៅក្នុងដំណាក់កាលណាមួយ អ្នកក៏នឹងត្រូវបញ្ជាក់ថាអ្នកជាផ្នែកនៃក្រុមដែលមានសិទ្ធិទទួលបាននៅពេលបច្ចុប្បន្នផងដែរ។ នេះត្រូវបានហៅថា “ការបញ្ជាក់”។

ដោយផ្អែកលើកន្លែងដែលអ្នកកក់ការណាត់ជួបរបស់អ្នក អ្នកអាចនឹងត្រូវបានស្នើសុំឱ្យមានការបញ្ជាក់ផ្សេងគ្នា។ អ្នកអាចនឹងត្រូវបានស្នើសុំឱ្យបញ្ជាក់តាមអ៊ីនធឺណិត ឬដោយនិយាយតាមទូរសព្ទនៅពេលកក់ដើម្បីបញ្ជាក់ថាអ្នកត្រូវតាមលក្ខណៈវិនិច្ឆ័យអំពីភាពមានសិទ្ធិទទួលបាននៅពេលបច្ចុប្បន្ន។

ប្រសិនបើអ្នកមិនត្រូវបានស្នើសុំការបញ្ជាក់នៅពេលកំពុងកក់ទេ អ្នកនឹងត្រូវបានស្នើសុំឱ្យបញ្ជាក់នៅពេលដែលអ្នកមកដល់ការណាត់ជួបរបស់អ្នក។
ទីតាំងចាក់វ៉ាក់សាំងទំនងនឹងមានទម្រង់បែបបទបញ្ជាក់សម្រាប់ឱ្យអ្នកបំពេញ ទោះយ៉ាងណា អ្នកអាចបំពេញ ទម្រង់បែបបទបញ្ជាក់ការចាក់វ៉ាក់សាំងបង្ការជំងឺ COVID-19 ប្រចាំរដ្ឋ Massachusetts និងយកវាតាមខ្លួនមកការណាត់ជួបរបស់អ្នកដើម្បីត្រៀមខ្លួន។

សូមចំណាំថាអ្នកមិនចាំបាច់ផ្ដល់ឯកសារជាលាយលក្ខណ៍អក្សរណាមួយពីអ្នកផ្ដល់សេវាវេជ្ជសាស្ត្ររបស់អ្នកដើម្បីបញ្ជាក់ស្ថានភាពវេជ្ជសាស្ត្របច្ចុប្បន្នរបស់អ្នកទេ។ ទីតាំងចាក់វ៉ាក់សាំងនឹងយកការបញ្ជាក់ផ្ទាល់ខ្លួនរបស់អ្នកធ្វើជាភស្តុតាងដែលអ្នកមានសិទ្ធិទទួលបាន ហើយនឹងកក់ទុកការណាត់ជួបរបស់អ្នក។

ទោះយ៉ាងណា ក្នុងនាមជាអ្នកជំងឺរបស់ Atrius Health ប្រសិនបើអ្នកមានសំណួរណាមួយអំពីថាតើអ្នកមានស្ថានភាពវេជ្ជសាស្ត្រដែលមានសិទ្ធិទទួលបានណាមួយឬទេ អ្នកអាចធ្វើដូចខាងក្រោម៖

- ចូលគណនី MyHealth របស់អ្នក ចុចលើ “Health Summary” ហើយបន្ទាប់មក “Health Issues” (សូមចំណាំថាបញ្ជីនេះអាចនឹងមិនត្រឹមត្រូវ ឬថ្មីជានិច្ចទេ ជាពិសេសប្រសិនបើអ្នកមិនបានជួបអ្នកផ្ដល់សេវារបស់អ្នកនៅប៉ុន្មានខែថ្មីៗនេះ)
- ផ្ញើសារទៅអ្នកផ្ដល់សេវាថែទាំបឋមរបស់អ្នកតាមរយៈ MyHealth
- ទូរសព្ទទៅការិយាល័យអ្នកផ្ដល់សេវាថែទាំបឋមរបស់អ្នកតាមទូរសព្ទ

## តើ ATRIUS HEALTH នឹងទាក់ទងមកខ្ញុំដើម្បីកំណត់ពេលណាត់ជួបនៅពេលណា?

Atrius Health កំពុងអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលសាធារណៈប្រចាំរដ្ឋ Massachusetts ។ គោលការណ៍ណែនាំទាំងនេះកំណត់ថា តើពេលណាបុគ្គលម្នាក់ៗអាចទទួលបានវ៉ាក់សាំង។

យើងនឹងទាក់ទងទៅអ្នកជំងឺដែលមានសិទ្ធិទទួលបានវ៉ាក់សាំងតាមរយៈផតថលរបស់អ្នកជំងឺ (MyHealth) ឬតាមរយៈទូរសព្ទ ឬសារជាអក្សរ នៅពេលដែលដល់វេនអ្នកដើម្បីកំណត់ពេលណាត់ជួប។ យើងក៏នឹងចែករំលែកព័ត៌មានថ្មីៗតាមរយៈអ៊ីមែល និងតាមរយៈគេហទំព័ររបស់យើងផងដែរ។

យើងទទួលបានការដឹកជញ្ជូនវ៉ាក់សាំងរៀងរាល់សប្ដាហ៍ពីរដ្ឋ។ ការផ្គត់ផ្គង់វ៉ាក់សាំងបច្ចុប្បន្នរបស់យើងគឺនៅមានកម្រិតខ្លាំងណាស់។ វាអាចនឹងចំណាយពេលវេលាខ្លះៗសម្រាប់យើងក្នុងការទាក់ទងទៅអ្នកដើម្បីកំណត់ពេលណាត់ជួប។

យើងចង់ឱ្យអ្នកទទួលបានវ៉ាក់សាំង មិនថាតែនៅ Atrius Health ឬក៏កន្លែងចាក់វ៉ាក់សាំងផ្សេងទៀតទេ។

## តើខ្ញុំកំណត់ពេលណាត់ជួបនៅ ATRIUS HEALTH សម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺ COVID-19 របស់ខ្ញុំដោយរបៀបណា?

នៅពេលដែលយើងទទួលបានវ៉ាក់សាំងពីរដ្ឋ យើងនឹងទាក់ទងទៅអ្នកជំងឺដែលមានសិទ្ធិទទួលបានវ៉ាក់សាំង តាមរយៈ MyHealth ឬតាមរយៈសារជាអក្សរ ឬការហៅទូរសព្ទដើម្បីអញ្ជើញពួកគេឱ្យកំណត់ពេលណាត់ជួប។

ការណាត់ជួបទាំងអស់ត្រូវបានកំណត់ពេលវេលានៅថ្នាក់កណ្តាល។ MyHealth គឺជាវិធីងាយស្រួលបំផុតដើម្បីកំណត់ពេលណាត់ជួប។ ចុះឈ្មោះនៅទីនេះ ហើយទាញយក កម្មវិធីទូរសព្ទចល័ត សម្រាប់ភាពងាយស្រួលបន្ថែម។

ប្រសិនបើអ្នកមិនមានអ៊ីនធឺណិតទេ យើងនឹងផ្តល់វិធីសម្រាប់អ្នកដើម្បីហៅទូរសព្ទទៅមជ្ឈមណ្ឌលទទួលទូរសព្ទរបស់ពួកយើងដើម្បីធ្វើការណាត់ជួប។

សូមកុំទាក់ទងទៅការិយាល័យវេជ្ជបណ្ឌិតរបស់អ្នកដើម្បីសួរអំពីណាត់ជួបចាក់វ៉ាក់សាំង។

សូមមើលផ្នែក ព័ត៌មានវ៉ាក់សាំង នៅលើវិបសាយរបស់យើងសម្រាប់ព័ត៌មានថ្មីៗ។

## ខ្ញុំមិនមានអ៊ីនធឺណិតទេ តើខ្ញុំគួរធ្វើដូចម្តេច?

ប្រសិនបើអ្នកមិនមានគណនី MyHealth ឬមិនមានអ៊ីនធឺណិតទេ យើងនឹងផ្តល់លេខទូរស័ព្ទឱ្យអ្នកដើម្បីកំណត់ពេលការណាត់ជួប នៅពេលយើងទាក់ទងទៅអ្នក។

រដ្ឋក៏បានបង្កើតមជ្ឈមណ្ឌលទទួលទូរសព្ទសម្រាប់ប្រជាជនដែលមិនមានអ៊ីនធឺណិតដើម្បីជួយកំណត់ពេលការណាត់ជួបនៅមជ្ឈមណ្ឌលចាក់វ៉ាក់សាំងប្រចាំរដ្ឋ Massachusetts ។ អ្នកអាចទូរសព្ទដោយឥតគិតថ្លៃតាមលេខ 2-1-1 ឬ (877) 211-6277 ពីថ្ងៃចន្ទ ដល់ ថ្ងៃព្រហស្បតិ៍ ពីម៉ោង 8:30 ព្រឹក ដល់ម៉ោង 8:00 យប់ និងពីថ្ងៃសុក្រ ដល់ ថ្ងៃអាទិត្យ ពីម៉ោង 8:30 ព្រឹក ដល់ ម៉ោង 5:00 ល្ងាច។

## តើទីតាំងរបស់ ATRIUS HEALTH មួយណាដែលនឹងមានវ៉ាក់សាំង?

ដូចបានណែនាំដោយរដ្ឋ យើងកំពុងចាត់ចែងទីតាំង Atrius Health ពិសេស សម្រាប់ជាមជ្ឈមណ្ឌលចាក់វ៉ាក់សាំង។

បច្ចុប្បន្ន គ្លីនិកត្រូវបានកំណត់នៅក្នុងការិយាល័យប្រចាំនៅ Boston (Kenmore), Chelmsford, Norwood និង Plymouth។

ប្រសិនបើទីតាំងរបស់យើងមិនដំណើរការសម្រាប់អ្នក សូមពិនិត្យ គេហទំព័រអំពីវ៉ាក់សាំងបង្ការជំងឺ COVID-19 របស់រដ្ឋ ដើម្បីស្វែងរកកន្លែងផ្សេងទៀតនៅក្នុងរដ្ឋ Massachusetts ដើម្បីកំណត់ពេលការចាក់វ៉ាក់សាំង។

រដ្ឋក៏បានបង្កើតមជ្ឈមណ្ឌលហៅទូរសព្ទសម្រាប់ប្រជាជនដែលមិនមានអ៊ីនធឺណិតដើម្បីជួយកំណត់ពេលណាត់ជួបនៅឯមជ្ឈមណ្ឌលចាក់វ៉ាក់សាំងរបស់រដ្ឋ។ អ្នកអាចហៅទូរសព្ទដោយឥតគិតថ្លៃតាមលេខ 2-1-1 ឬ (877) 211-6277ពីថ្ងៃចន្ទ ដល់ថ្ងៃព្រហស្បតិ៍ ម៉ោង 8:30 ព្រឹកដល់ 8:00 យប់ និងថ្ងៃសុក្រ ដល់ថ្ងៃអាទិត្យម៉ោង 8:30 ព្រឹកដល់ 5:00 ល្ងាច។

យើងចង់ឱ្យអ្នកទទួលបានវ៉ាក់សាំង ទោះនៅ Atrius Health ឬនៅទីតាំង ផ្សេងទៀត។

## តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំមិនអាចរកឃើញការណាត់ជួបនៅ ATRIUS HEALTH?

បរិមាណវ៉ាក់សាំងរបស់ពួកយើងពីរដ្ឋគឺមានកម្រិតខ្លាំងណាស់នៅពេលបច្ចុប្បន្ន។ ការណាត់ជួបកក់បានយ៉ាងលឿនចំពោះអ្នកជំងឺដែលមានសិទ្ធិទទួលវ៉ាក់សាំង។

ប្រសិនបើអ្នកមិនអាចស្វែងរកការណាត់ជួបឃើញទេ សូមព្យាយាមម្តងទៀត។ ការណាត់ជួបថ្មីៗនឹងត្រូវបានបន្ថែម នៅពេលយើងទទួលបានវ៉ាក់សាំងបន្ថែមពីរដ្ឋ និងក្នុងករណីដែលប្រជាជនលុបចោលការណាត់ជួប។

## ប្រសិនបើខ្ញុំហៅតាមទូរសព្ទ តើមានការណាត់ជួបច្រើនជាងដែរឬទេ នៅ **ATRIUS HEALTH?**

ទេ។ ភាពមាននៃការណាត់ជួបគឺដូចគ្នា មិនថាអ្នកកក់ទុកតាម MyHealth ឬតាមទូរសព្ទជាមួយមជ្ឈមណ្ឌលទទួលទូរសព្ទទេ។

## តើគ្រួសារ ឬអ្នកផ្តល់ការថែទាំរបស់ខ្ញុំអាចទទួលបានការចាក់វ៉ាក់សាំងជាមួយខ្ញុំដែរឬទេ ប្រសិនបើខ្ញុំនាំពួកគេទៅការណាត់ជួបរបស់ខ្ញុំ?

ទេ។ ទីតាំង Atrius Health នីមួយៗមានវ៉ាក់សាំងគ្រប់គ្រាន់នៅក្នុងដៃសម្រាប់តែការណាត់ជួបដែលបានកំណត់ពេលសម្រាប់ថ្ងៃនីមួយៗប៉ុណ្ណោះ។ យើងមិនអាចចាក់វ៉ាក់សាំងដល់មនុស្សដែលជូនដំណើរអ្នកមកតាមការណាត់ជួបរបស់អ្នកបានទេ។

## តើខ្ញុំត្រូវតែជាអ្នកជំងឺរបស់ **ATRIUS HEALTH** ទើបអាចចាក់វ៉ាក់សាំងបាននៅកន្លែងអ្នកឬ?

មែនហើយ។ មានតែអ្នកជំងឺរបស់ Atrius Health ដែលមានសិទ្ធិទទួលបានប៉ុណ្ណោះដែលអាចទទួលបានការចាក់វ៉ាក់សាំងនៅឯគ្លីនិកអ្នកជំងឺរបស់យើង។ ប្រសិនបើអ្នកមិនបានទទួលការថែទាំពី Atrius Health ទេ សូមពិនិត្យមើល គេហទំព័រអំពីវ៉ាក់សាំងបង្ការជំងឺ COVID-19 របស់រដ្ឋ សម្រាប់ទីតាំងផ្សេងទៀតនៅក្នុងរដ្ឋ Massachusetts ដែលអ្នកអាចកំណត់ពេលចាក់វ៉ាក់សាំងបាន។ អ្នកក៏អាចចុះឈ្មោះជាមុនសម្រាប់ការណាត់ជួបចាក់វ៉ាក់សាំងបង្ការជំងឺ COVID-19 នៅទីតាំងមួយក្នុងចំណោមទីតាំងចាក់វ៉ាក់សាំងចំនួន 7 របស់រដ្ឋដោយចូលទៅ https://vaccinesignup.mass.gov។

## តើវ៉ាក់សាំងម៉ាកណាដែល **ATRIUS HEALTH** មានសម្រាប់អ្នកជំងឺ?

បច្ចុប្បន្នយើងកំពុងទទួលបានវ៉ាក់សាំង Moderna ភាគច្រើនពីរដ្ឋ។ Moderna ត្រូវបានអនុម័តសម្រាប់តែមនុស្សដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅតែប៉ុណ្ណោះ។ យើងទទួលបានវ៉ាក់សាំង Janssen (Johnson & Johnson) ម្តងម្កាលក្នុងបរិមាណតិចតួចបំផុត។ វ៉ាក់សាំង Janssen (Johnson & Johnson) ក៏ត្រូវបានអនុម័តសម្រាប់តែអ្នកដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅផងដែរ។ ទន្ទឹមនឹងនេះ យើងក៏អាចត្រឹមតែចាក់វ៉ាក់សាំងដល់អ្នកជំងឺដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅតែប៉ុណ្ណោះ។ សូមកត់សម្គាល់ថា យើងមិនអាចផ្តល់ជូនដល់អ្នកជំងឺនូវជម្រើសវ៉ាក់សាំងដែលពួកគេចង់ចាក់បានទេ។

## តើត្រូវចំណាយប្រាក់ក្នុងការទទួលវ៉ាក់សាំងដែរឬទេ?

មិនមានការគិតថ្លៃចំពោះអ្នកសម្រាប់ការទទួលវ៉ាក់សាំងទេ។

## តើវ៉ាក់សាំងមានសុវត្ថិភាព និងមានប្រសិទ្ធភាពឬទេ?

វ៉ាក់សាំងបង្ការជំងឺ COVID-19 ដែលត្រូវបានអនុម័តទាំងបីគឺមានសុវត្ថិភាព និងមានប្រសិទ្ធភាពខ្ពស់ប្រឆាំងនឹងជំងឺធ្ងន់ធ្ងរ ការចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ និងមរណភាព។

វ៉ាក់សាំង Janssen (Johnson & Johnson) បានផ្តល់ការបង្ការ 93% ប្រឆាំងនឹងការចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យដោយសារជំងឺ COVID-19 ។ វ៉ាក់ត្រូវបានបង្ហាញថាមានប្រសិទ្ធភាពប្រឆាំងនឹងមេរោគបម្លែងខ្លួនថ្មីនៃជំងឺ COVID-19 ដោយមានការស្រាវជ្រាវត្រូវបានធ្វើឡើងនៅក្នុងប្រទេសដែលមានមេរោគបម្លែងខ្លួនទាំងនេះចម្លងកាន់តែច្រើន រួមមានប្រទេសអាហ្វ្រិកខាងត្បូង និងប្រទេសប្រេស៊ីល។ អត្ថប្រយោជន៍បន្ថែមគឺថា វ៉ាក់សាំង Janssen (Johnson & Johnson) តម្រូវឱ្យចាក់តែម្តងប៉ុណ្ណោះ – ដូច្នេះប្រសិនបើអ្នកត្រូវបានគេផ្តល់វ៉ាក់សាំងនេះឱ្យ នោះអ្នក "ចាក់តែម្តងរួចរាល់" ហើយមិនចាំបាច់ធ្វើការណាត់ជួបជាលើកទីពីរទេ។

មុនពេលផ្តល់ឱ្យប្រជាជនទូទៅ អ្នកបង្កើតវ៉ាក់សាំងពិតជាបានសិក្សាដើម្បីឱ្យប្រាកដថាវ៉ាក់សាំងទាំងនេះមានប្រសិទ្ធភាពមែន។

យើងបានដឹងអំពីបច្ចេកវិទ្យាដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើតវ៉ាក់សាំង Moderna និង Pfizer ជាច្រើនទសវត្សរ៍មកហើយ។ អ្នកវិទ្យាសាស្ត្រអាចប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រចុងក្រោយបំផុតដើម្បីស្វែងយល់ជាច្រើនយ៉ាងលឿនអំពីវីរុស និងប្រើប្រាស់បច្ចេកវិទ្យា mRNA ។

មន្ត្រីរបស់ Healthcare អ្នកជំនាញសុខភាពសាធារណៈ និងអ្នកវិទ្យាសាស្ត្រដទៃទៀតដែលមិនបានពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការបង្កើតវ៉ាក់សាំង ក៏បានពិនិត្យមើលរាល់វិទ្យាសាស្ត្រ និងការសិក្សាមុនពេលវ៉ាក់សាំងនីមួយៗត្រូវបានអនុញ្ញាត។

## តើខ្ញុំគួរតែពន្យារពេល ឬមិនទទួលវ៉ាក់សាំងសម្រាប់មូលហេតុណាមួយឬទេ?

អ្នកត្រូវបានណែនាំឱ្យពន្យារពេលការចាក់វ៉ាក់សាំង ប្រសិនបើៈ

- អ្នកមានអារម្មណ៍ថាមិនស្រួលខ្លួននៅពេលចាក់វ៉ាក់សាំង (គ្រុនក្តៅ ហត់ដង្ហក់ ក្អួត រាក ឬជំងឺស្រួចស្រាវ)។
- អ្នកត្រូវបានធ្វើកោសលវិនិច្ឆ័យថាមានជំងឺ COVID-19 នៅក្នុងរយៈពេល 14 ថ្ងៃចុងក្រោយ ហើយមិនទាន់ត្រូវតាមលក្ខណៈវិនិច្ឆ័យដើម្បីឈប់ដាក់ខ្លួនឱ្យដាច់ដោយឡែកនៅឡើយ។
- អ្នកបានទទួលវ៉ាក់សាំងផ្សេងទៀតនៅក្នុងរយៈពេល 14 ថ្ងៃចុងក្រោយ។

អ្នកត្រូវបានណែនាំមិនឱ្យទទួលវ៉ាក់សាំង ប្រសិនបើៈ

- អ្នកមានប្រវត្តិនៃប្រតិកម្មអាលែកហ្ស៊ីភ្លាមៗបន្ទាប់ពីដូសនៃវ៉ាក់សាំងបង្ការជំងឺ COVID-19 នៃ mRNA ពីមុន ឬសមាសធាតុណាមួយរបស់វ៉ាក់សាំងនេះ (រួមទាំង polyethylene glycol[PEG]) ឬមានប្រតិកម្មអាលែកហ្ស៊ីភ្លាមៗនៅកម្រិតធ្ងន់ធ្ងរណាមួយចំពោះ polysorbate ។

## តើវ៉ាក់សាំងអាចផ្តល់ជំងឺ **COVID-19** ដល់ខ្ញុំដែរឬទេ?

ទេ។ គ្មានវ៉ាក់សាំងណាមានផ្ទុកវីរុសនៅរស់ទេ ដូច្នេះវ៉ាក់សាំងមិនអាចផ្តល់ឱ្យអ្នកនូវជំងឺ COVID-19 ឡើយ។

## តើវ៉ាក់សាំងប្រឆាំងនឹងមេរោគបម្លែងខ្លួនថ្មីនៃជំងឺ **COVID-19** ដែរឬទេ?

ឥឡូវនេះអ្នកស្រាវជ្រាវកំពុងពិនិត្យមើលរឿងនេះ។ ការស្រាវជ្រាវដំបូងបង្ហាញថាវ៉ាក់សាំងដែលបានអនុម័តផ្តល់ការបង្ការ ដែលប្រហែលជាមានការថយចុះបន្តិចបន្តួចប្រឆាំងនឹងមេរោគបម្លែងខ្លួនដែលគេស្គាល់។ ដំណឹងល្អគឺថា តាមរបៀបដូចគ្នាដែលវ៉ាក់សាំងផ្តាសាយត្រូវបានកែតម្រូវជារៀងរាល់ឆ្នាំ ដើម្បីប្រឆាំងនឹងមេរោគជំងឺផ្តាសាយដែរ ការចាក់វ៉ាក់សាំងបង្ការជំងឺ COVID-19 បន្ថែម ឬវ៉ាក់សាំងប្រចាំឆ្នាំអាចត្រូវបានកែប្រែដើម្បីធ្វើការប្រឆាំងនឹងមេរោគសំខាន់ៗ។

## តើខ្ញុំគួររំពឹងទុកអ្វីខ្លះនៅការណាត់ជួបរបស់ខ្ញុំ?

អ្នកដែលផ្តល់វ៉ាក់សាំងឱ្យអ្នកនឹងសួរអ្នកនូវសំណួរមួយចំនួន ហើយបន្ទាប់មកចាក់វ៉ាក់សាំងឱ្យអ្នក។

អ្នកនឹងត្រូវបានគេសង្កេតតាមដានយ៉ាងហោចណាស់រយៈពេល 15 នាទី បន្ទាប់ពីការចាក់វ៉ាក់សាំងរួច។

ប្រសិនបើអ្នកមានប្រតិកម្មអាលែកហ្ស៊ីទៅនឹងថ្នាំចាក់ ឬវ៉ាក់សាំងផ្សេងទៀតកាលពីពេលមុន ឬប្រសិនបើអ្នកមានប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរ (ប្រតិកម្មថ្នាំ) ពីមូលហេតុណាមួយដែល អ្នកនឹងត្រូវបានគេសង្កេតតាមដានក្នុងរយៈពេល 30 នាទី។

អ្នកនឹងទទួលបានកាតចាក់វ៉ាក់សាំងមួយដែលប្រាប់អ្នកថាវ៉ាក់សាំងបង្ការជំងឺ COVID-19 មួយណាដែលអ្នកបានទទួល កាលបរិច្ឆេទដែលអ្នកបានទទួលវា និងកន្លែងដែលអ្នកបានទទួលវា។

ប្រសិនបើអ្នកបានទទួល Prifzer ឬ Moderna នោះដូសទីពីររបស់អ្នកនឹងត្រូវបានកំណត់ពេលវេលាទុក។ ប្រសិនបើអ្នកបានទទួល Janssen (Johnson & Johnson) វាជាវ៉ាក់សាំងមួយដូស ដូច្នេះអ្នកនឹងត្រូវបានចាក់វ៉ាក់សាំងយ៉ាងពេញលេញ។

## តើវ៉ាក់សាំងមានផលរំខានដែរឬទេ?

ដូចគ្នានឹងការចាក់វ៉ាក់សាំងជំងឺផ្តាសាយ ឬវ៉ាក់សាំងដទៃទៀតដែរ អ្នកអាចនឹងមានផលរំខានខ្លះ។ ទាំងនេះគឺជាសញ្ញាបង្ហាញថាវ៉ាក់សាំងកំពុងដំណើរការ ហើយរាងកាយកំពុងបង្កើតភាពស៊ាំនឹងមេរោគ។ ផលរំខានភាគច្រើនមិនបង្កឱ្យមានការព្រួយបារម្ភទេ ហើយវានឹងបាត់ទៅវិញក្នុងរយៈពេលមួយថ្ងៃឬពីរថ្ងៃ។ មនុស្សមួយចំនួនរាយការណ៍ថាមានអារម្មណ៍ថាមានផលរំខានច្រើនទៀត ក្រោយពីការចាក់ដូសលើកទីពីរដោយប្រើវ៉ាក់សាំងពីរដូស។ អ្នកគួរតែនៅផ្ទះ ប្រសិនបើអ្នកក្តៅខ្លួន។

ផលរំខានជាទូទៅរួមមានៈ

- ឈឺចាប់នៅកន្លែងចាក់
- អស់កម្លាំង
- ឈឺក្បាល
- ឈឺសាច់ដុំ
- ព្រឺរងារ
- ឈឺសន្លាក់
- គ្រុនក្តៅ

## តើខ្ញុំគួរចាក់វ៉ាក់សាំងប្រភេទដដែលឬ ប្រសិនបើវាត្រូវការពីរដូស?

មែនហើយ។ អ្នកគួរតែចាក់វ៉ាក់សាំងម៉ាកតែមួយសម្រាប់ដូសទាំងពីរ។

## តើដូសលើកទីពីររបស់ខ្ញុំនឹងត្រូវបានកំណត់ពេលវេលានៅពេលណា?

ដូសលើកទីពីររបស់អ្នកនឹងត្រូវបានកំណត់ពេលនៅពេលដែលអ្នកមកជួបនៅដូសទីមួយរបស់អ្នក។

ដូស Pfizer / BioNTech ត្រូវបានគេណែនាំឲ្យមានចន្លោះពេលប្រមាណជា 21 ថ្ងៃ ហើយដូស Moderna ត្រូវបានគេណែនាំឲ្យមានចន្លោះពេលប្រមាណជា 28 ថ្ងៃ។

## តើវាមិនអីទេឬ ប្រសិនបើដូសទីពីររបស់ខ្ញុំមិនចាក់ចំថ្ងៃដែលបានណែនាំ?

ប្រសិនបើអ្នកទទួលវ៉ាក់សាំងដែលតម្រូវឱ្យចាក់ចំនួនពីរដូស អ្នកគួរតែទទួលការចាក់លើកទីពីររបស់អ្នកឱ្យកៀកនឹងចន្លោះពេលដែលបានណែនាំតាមដែលអាចធ្វើទៅបាន។ ទោះយ៉ាងណា ដូសទីពីររបស់អ្នកអាចនឹងផ្តល់ឱ្យរហូតដល់ទៅ 6 សប្តាហ៍ (42 ថ្ងៃ) បន្ទាប់ពីដូសទីមួយ ប្រសិនបើចាំបាច់។ អ្នកមិនគួរទទួលដូសទីពីរឆាប់ជាងចន្លោះពេលដែលបានណែនាំឡើយ។

## តើខ្ញុំនឹងមានភាពស៊ាំពេញលេញពីវ៉ាក់សាំងនៅពេលណា?

មនុស្សត្រូវបានចាត់ទុកថាបានចាក់វ៉ាក់សាំងពេញលេញនៅរយៈពេល 2 សប្តាហ៍ក្រោយពីដូសទីពីររបស់ពួកគេនៅក្នុងស៊េរី 2 ដូស ដូចជាវ៉ាក់សាំង Pfizer ឬ Moderna ឬ 2 សប្តាហ៍បន្ទាប់ពីវ៉ាក់សាំងតែមួយដូស ដូចជាវ៉ាក់សាំង Johnson’s Janssen ។ វាអាចទៅរួចដែលថាអ្នកអាចឆ្លងជំងឺ COVID-19 នៅក្នុងរយៈពេលពីរបីថ្ងៃមុនពេល ឬបន្ទាប់ពីទទួលវ៉ាក់សាំង។

ទោះបីបន្ទាប់ពីអ្នកទទួលដូសនៃវ៉ាក់សាំងដែលត្រូវបានតម្រូវក៏ដោយ សូមបន្តជៀសវាងកន្លែងក្នុងអគារដែលមានមនុស្សច្រើន រក្សាគម្លាតរាងកាយ ពាក់ម៉ាស់ក្រណាត់នៅក្នុងកន្លែងសាធារណៈ និងអនុវត្តអនាម័យល្អ។

## តើកុមារអាចទទួលវ៉ាក់ស□□ងបានដែរឬទេ?

ទេ មិនមែននៅពេលនេះទេ។

វ៉ាក់សាំង Pfizer/BioNTech ត្រូវបានអនុម័តសម្រាប់មនុស្សដែលមានអាយុចាប់ពី 16 ឆ្នាំឡើង។ ទាំងវ៉ាក់សាំង Moderna vaccine និង the Janssen (Johnson & Johnson) ត្រូវបានអនុម័តសម្រាប់មនុស្សដែលមានអាយុចាប់ពី 18 ឆ្នាំឡើង។

វ៉ាក់សាំង Pfizer និង Moderna បានចាប់ផ្តើមការព្យាបាលសាកល្បងសម្រាប់កុមារដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅហើយ។ វាមិនត្រូវបានគេដឹងទេថា តើលទ្ធផលនៃការសិក្សាទាំងនេះនឹងមាននៅពេលណានោះទេ។

## ខ្ញុំមានជំងឺ **COVID-19** ហើយខ្ញុំបានធូរស្បើយហើយ។ តើខ្ញុំនៅតែគួរទទួលយកវ៉ាក់សាំងដែរឬទេ?

មែនហើយ។ ដោយសារវាអាចទៅរួចក្នុងការធ្លាក់ខ្លួនឈឺម្តងទៀតដោយសារជំងឺ COVID-19 ដូច្នេះអ្នកគួរតែចាក់វ៉ាក់សាំង។

ប្រសិនបើអ្នកត្រូវបានព្យាបាលជំងឺ COVID-19 របស់អ្នកដោយអង់ទីករម៉ូណូក្លូន ឬប្លាស្មារបស់អ្នកជំងឺដែលទើបងើបពីឈឺ អ្នកគួរតែរង់ចាំរយៈពេល 90 ថ្ងៃ មុនពេលចាក់វ៉ាក់សាំង។

ពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នក ប្រសិនបើអ្នកមិនប្រាកដថាតើអ្នកបានទទួលការព្យាបាលមួយណា ឬប្រសិនបើអ្នកមានសំណួរបន្ថែមទៀតអំពីការចាក់វ៉ាក់សាំងបង្ការជំងឺ COVID-19 ។

## តើខ្ញុំគួរតែចាក់វ៉ាក់សាំងដែរឬទេ ប្រសិនបើខ្ញុំសង្ឃឹមថានឹងមានផ្ទៃពោះឆាប់ៗនោះ?

វ៉ាក់សាំងមិនប៉ះពាល់ដល់លទ្ធភាពបន្តពូជនោះទេ។ វាអាចនឹងមានប្រយោជន៍ក្នុងការទទួលយកវ៉ាក់សាំងមុនពេលដែលអ្នកមានផ្ទៃពោះ ដើម្បីកាត់បន្ថយការឆ្លងជំងឺ COVID-19 ខណៈពេលមានផ្ទៃពោះ។

## តើខ្ញុំអាចចាក់វ៉ាក់សាំងដែរឬទេ ប្រសិនបើខ្ញុំមានផ្ទៃពោះឬកំពុងបំបៅដោះកូន?

អ្នកដែលមានផ្ទៃពោះ និងមានសិទ្ធិទទួលបានវ៉ាក់សាំងបង្ការជំងឺ COVID-19 អាចចាក់វ៉ាក់សាំងបាន ប្រសិនបើពួកគេសម្រេចចិត្តថាពួកគេចង់ចាក់។ អ្នកដែលមានផ្ទៃពោះ និងមានសំណួរអំពីវ៉ាក់សាំងអាចនិយាយជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់ពួកគេបាន។ ការទទួលបានព័ត៌មាន និងចម្លើយអំពីហានិភ័យនិងអត្ថប្រយោជន៍ជាក់លាក់ អាចជួយក្នុងការសម្រេចចិត្តបាន។

មិនមានព័ត៌មានច្រើនទេអំពីសុវត្ថិភាពរបស់វ៉ាក់សាំងបង្ការជំងឺ COVID-19 ចំពោះស្ត្រីដែលកំពុងបំបៅដោះកូន។ ដូច្នេះ យើងមិនដឹងអំពីផលរំខានដែលវ៉ាក់សាំង mRNA អាចនឹងមានចំពោះទារកដែលបៅដោះម្តាយ ឬចំពោះផលិតផលទឹកដោះនោះទេ។ អ្នកវិទ្យាសាស្ត្រមិនគិតថាវ៉ាក់សាំង mRNA ជាហានិភ័យចំពោះទារកដែលកំពុងបៅដោះម្តាយទេ។ អ្នកដែលកំពុងបំបៅកូន ហើយមានសិទ្ធិទទួលបានវ៉ាក់សាំងបង្ការជំងឺ COVID-19 អាចទទួលវ៉ាក់សាំងបាន ប្រសិនបើពួកគេសម្រេចចិត្តថាពួកគេចង់ចាក់។

## តើខ្ញុំគួរតែទទួលយកវ៉ាក់សាំងដែរឬទេ ប្រសិនបើខ្ញុំមានប្រព័ន្ធភាពស៊ាំដែលចុះខ្សោយ?

ប្រសិនបើអ្នកមានស្ថានភាពជំងឺ ឬលេបថ្នាំដែលធ្វើឱ្យចុះខ្សោយសមត្ថភាពក្នុងការប្រយុទ្ធនឹងការឆ្លងជំងឺ អ្នកអាចនឹងមានជំងឺកាន់តែធ្ងន់ធ្ងរជាងមនុស្សដទៃ ប្រសិនបើអ្នកឆ្លងជំងឺ COVID-19 ។ ប្រសិនបើអ្នកមានប្រព័ន្ធភាពស៊ាំចុះខ្សោយ អ្នកអាចទទួលយកវ៉ាក់សាំងបាន ដរាបណាមិនមានមូលហេតុផ្សេងទៀតដែលថាអ្នកមិនអាចទទួលយកវ៉ាក់សាំងបានទេនោះ។

មានព័ត៌មានតិចតួចអំពីថាតើវ៉ាក់សាំង mRNA មានសុវត្ថិភាព និងមានប្រសិទ្ធភាពកម្រិតណាចំពោះមនុស្សដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ។ អ្នកដែលមានជំងឺមហារីក ការបណ្តុះសរីរាង្គ ឬការប្រើប្រាស់ថ្នាំផ្សេងទៀតនៅតែអាចទទួលយកវ៉ាក់សាំងបង្ការជំងឺ COVID-19 ប្រភេទ mRNA បាន។ ទោះបីជាវ៉ាក់សាំងទំនងជាមានសុវត្ថិភាព និងមានប្រសិទ្ធភាព ការឆ្លើយតបទៅនឹងវ៉ាក់សាំងអាចនឹងត្រូវបានកាត់បន្ថយ។

## តើគួរតែចាក់វ៉ាក់សាំងដែរឬទេ ប្រសិនបើខ្ញុំមានអាលែកហ្ស៊ី?

ប្រសិនបើអ្នកត្រូវបានព្យាបាលសម្រាប់ប្រតិកម្មអាលែកហ្ស៊ីក្នុងរយៈពេល បួនម៉ោងក្រោយការទទួលដូសទីមួយនៃវ៉ាក់សាំងបង្ការជំងឺ COVID-19 ប្រភេទ mRNA របស់អ្នក នោះអ្នកមិនគួរទទួលយកវ៉ាក់សាំងម្តងទៀតទេ។ អ្នកក៏មិនគួរទទួលយកវ៉ាក់សាំងផងដែរ ប្រសិនបើអ្នកធ្លាប់មានប្រតិកម្មអាលែកហ្ស៊ីក្នុងរយៈពេល 4 ម៉ោងក្រោយការទទួលយកសារធាតុផ្សំណាមួយរបស់វ៉ាក់សាំងបង្ការជំងឺ COVID-19 ប្រភេទ mRNA ។

អ្នកដែលមានអាលែកហ្ស៊ីចំពោះសត្វចិញ្ចឹម អាហារ ថ្នាំដែលលេប ឬអាលែកហ្ស៊ីចំពោះវត្ថុផ្សេងទៀតដូចជាលម្អង។ល។ អាចចាក់វ៉ាក់សាំងបាន។ អ្នកដែលមានអាលែកហ្ស៊ីចំពោះថ្នាំ ឬវ៉ាក់សាំងចាក់ផ្សេងទៀត អាចចាក់វ៉ាក់សាំងបាន ប៉ុន្តែគួរតែពិនិត្យជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់ពួកគេដើម្បីពិភាក្សាអំពីហានិភ័យ និងអត្ថប្រយោជន៍មុនពេលទទួលយកវ៉ាក់សាំង។ អ្នកដែលមានប្រវត្តិប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរខ្លាំង អាចនឹងត្រូវបានស្នើសុំឱ្យនៅទទួលការសង្កេតរយៈពេល 30 នាទីបន្ទាប់ពីការទទួលយកវ៉ាក់សាំង។

## តើសារធាតុផ្សំនៅក្នុងវ៉ាក់សាំងមានអ្វីខ្លះ?

វ៉ាក់សាំង Pfizer, Moderna, abd Janssen មានសន្លឹកព័ត៌មានសង្ខេបដែលរៀបរាប់អំពីសារធាតុផ្សំរបស់វ៉ាក់សាំងនីមួយៗ។ សន្លឹកព័ត៌មានសង្ខេបទាំងនោះអាចរកបាននៅ៖

- សន្លឹកព័ត៌មានសង្ខេបអំពីការអនុញ្ញាតប្រើប្រាស់បន្ទាន់ (Emergency Use Authorization, EUA) នូវវ៉ាក់សាំងបង្ការជំងឺ COVID-19 ប្រភេទ Pfizer-BioNTech សម្រាប់អ្នកទទួល និងអ្នកផ្តល់ការថែទាំ (fda.gov) (ទំព័រទី 2)
- សន្លឹកព័ត៌មានសង្ខេបអំពីការអនុញ្ញាតប្រើប្រាស់បន្ទាន់ (Emergency Use Authorization, EUA) នូវវ៉ាក់សាំងបង្ការជំងឺ COVID-19 ប្រភេទ Moderna សម្រាប់អ្នកទទួល និងអ្នកផ្តល់ការថែទាំ (fda.gov) (ទំព័រទី 2)
- សន្លឹកព័ត៌មានសង្ខេបរបស់ទីភ្នាក់ងារឱសថអឺរ៉ុប (European Medicines Agency, EUA) នៃវ៉ាក់សាំងបង្ការជំងឺ COVID-19 ប្រភេទ Janssen សម្រាប់អ្នកទទួល និងអ្នកផ្តល់ការថែទាំ (fda.gov) (ទំព័រទី 2)

## តើខ្ញុំអាចចាប់ផ្តើមធ្វើអ្វីបានម្តងទៀតខ្លះ បន្ទាប់ពីខ្ញុំបានចាក់វ៉ាក់សាំងពេញលេញហើយ?

ប្រសិនបើអ្នកបានចាក់វ៉ាក់សាំងពេញលេញហើយ៖

- អ្នកអាចជួបជុំនៅក្នុងអគារជាមួយមនុស្សដែលបានចាក់វ៉ាក់សាំងពេញលេញដោយមិនបាច់ពាក់ម៉ាស់។
- អ្នកអាចជួបជុំក្នុងអគារជាមួយមនុស្សដែលមិនបានចាក់វ៉ាក់សាំងដែលមកពីគ្រួសារផ្សេងមួយទៀត (ឧទាហរណ៍ ការទៅលេងសាច់ញាតិដែលរស់នៅជុំគ្នា) ដោយមិនបាច់ពាក់ម៉ាស់ លើកលែងតែមនុស្សទាំងនោះ ឬនរណាម្នាក់ដែលពួកគេរស់នៅជាមួយមានហានិភ័យដែលកើនឡើងចំពោះជំងឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19 ។
- ប្រសិនបើអ្នកបាននៅជិតនរណាម្នាក់ដែលមានជំងឺ COVID-19 អ្នកមិនចាំបាច់នៅឆ្ងាយពីអ្នកដទៃ ឬធ្វើតេស្តនោះទេ លើកលែងតែអ្នកមានរោគសញ្ញា។
  - ទោះយ៉ាងណា ប្រសិនបើអ្នករស់នៅជាក្រុម (ដូចជាមន្ទីរអប់រំកែប្រែ ឬឃុំឃាំង ឬផ្ទះស្នាក់នៅជាក្រុម) ហើយនៅជិតនរណាម្នាក់ដែលមានជំងឺ COVID-19 អ្នកគួរតែនៅឆ្ងាយពីអ្នកដទៃរយៈពេល 14 ថ្ងៃ ហើយធ្វើតេស្ត ទោះបីជាអ្នកមិនមានរោគសញ្ញាក៏ដោយ។
  - ប្រសិនបើអ្នកជាបុគ្គលិកថែទាំសុខភាព អ្នកគួរតែទាក់ទងផ្នែកសុខភាពនិយោជិតរបស់អង្គការរបស់អ្នកសម្រាប់ការធ្វើតេស្តជាក់លាក់ ឬការណែនាំឱ្យធ្វើចត្តាឡីស័ក។
- ការផ្តល់ឱវាទអំពីការធ្វើដំណើរប្រចាំរដ្ឋ Massachusetts បានចែងថាអ្នកមកលេងដែលចូលក្នុងរដ្ឋ Massachusetts ត្រូវបានណែនាំឱ្យធ្វើចត្តាឡីស័ករយៈពេល 10 ថ្ងៃ នៅពេលការមកដល់របស់ពួកគេ ឬនៅពេលបង្កើតលទ្ធផលតេស្តអវិជ្ជមាន។ ទោះយ៉ាងណា មានការលើកលែងចំពោះការផ្តល់ឱវាទអំពីការធ្វើដំណើរនេះ ចំពោះអ្នកដែលបានចាក់វ៉ាក់សាំងពេលលេញ (ឧទា. អ្នកដែលបានទទួលវ៉ាក់សាំងបង្ការជំងឺ COVID-19 មិនថាប្រភេទ Moderna ឬ Pfizer ចំនួនពីរដូស ឬអ្នកដែលបានទទួលដូសតែមួយនៃវ៉ាក់សាំង Johnson & Johnson រយៈពេល 14 ថ្ងៃឡើងទៅកាលពីពេលកន្លងទៅ) និងអ្នកដែលមិនមានរោគសញ្ញា។

## តើខ្ញុំគួរតែបន្តធ្វើអ្វីខ្លះ បន្ទាប់ពីខ្ញុំទទួលបានការចាក់វ៉ាក់សាំងពេញលេញ?

- អ្នកនៅតែត្រូវចាត់វិធានការដើម្បីការពារខ្លួនអ្នក និងអ្នកដទៃក្នុងស្ថានភាពជាច្រើនដូចជា ការពាក់ម៉ាស ការស្នាក់នៅចម្ងាយយ៉ាងតិច 6 ហ្វីតពីអ្នកដទៃ និងជៀសវាងការជួបជុំ និងកន្លែងដែលមានខ្យល់ចេញចូលមិនល្អ។ អនុវត្តការប្រុងប្រយ័ត្នទាំងនេះនៅពេលណាដែលអ្នក៖
  - នៅទីសាធារណៈ:

- ○ ប្រមូលផ្តុំជាមួយនឹងមនុស្សដែលមិនបានចាក់វ៉ាក់សាំងមកពីគ្រួសារផ្សេងទៀតលើសពីមួយគ្រួសារ
  - ○ ការទៅសួរសុខទុក្ខអ្នកដែលមិនបានទទួលការចាក់វ៉ាក់សាំងមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរ ឬការស្លាប់ពីជំងឺ COVID-19 ឬអ្នកដែលរស់នៅជាមួយមនុស្សដែលមានហានិភ័យខ្ពស់
- អ្នកគួរតែបន្តជៀសវាងការប្រមូលផ្តុំដែលមានទំហំមធ្យមឬធំ។
- អ្នកគួរតែបន្តពន្យារពេលធ្វើដំណើរក្នុងស្រុក និងអន្តរជាតិ។ ប្រសិនបើអ្នកធ្វើដំណើរ អ្នកនៅតែត្រូវធ្វើតាមលក្ខខណ្ឌតម្រូវ និងអនុសាសន៍របស់ CDC។ អាស្រ័យលើកន្លែងដែលអ្នកធ្វើដំណើរ អ្នកអាចរកឃើញថារដ្ឋមានលក្ខខណ្ឌតម្រូវចំពោះការធ្វើដំណើរតឹងរឹងតិចតួចសម្រាប់មនុស្សដែលបានទទួលការចាក់វ៉ាក់សាំងពេញលេញ។
- អ្នកគួរតែបន្តប្រុងប្រយ័ត្នចំពោះរោគសញ្ញានៃជំងឺ COVID-19 ជាពិសេស ប្រសិនបើអ្នកបាននៅក្បែរអ្នកឈឺ។ ប្រសិនបើអ្នកមានរោគសញ្ញានៃជំងឺ COVID-19 អ្នកគួរតែទទួលបានការធ្វើតេស្ត និងស្នាក់នៅផ្ទះ និងនៅឆ្ងាយពីអ្នកដទៃ។
- អ្នកនឹងនៅតែត្រូវការធ្វើតាមការណែនាំនៅកន្លែងធ្វើការរបស់អ្នក។

## តើខ្ញុំត្រូវបន្តការពាក់ម៉ាស់ និងអនុវត្តការរក្សាគម្លាតសង្គមឬទេបន្ទាប់ពីខ្ញុំទទួលបានវ៉ាក់សាំង?

មែនហើយ។ សូម្បីតែបន្ទាប់ពីការទទួលបានវ៉ាក់សាំងក៏ដោយ ក៏មនុស្សគ្រប់គ្នាត្រូវពាក់ម៉ាស អនុវត្តការរក្សាគម្លាតសង្គម និងលាងដៃរបស់ពួកគេផងដែរ។ វានឹងត្រូវការពេលវេលាដើម្បីចាក់ថ្នាំបង្ការរោគឱ្យបានគ្រប់គ្រាន់ក្នុងចំណោមប្រជាជនដើម្បីបញ្ឈប់វីរុសពីការរីករាលដាល។

## សំណួរដែលសួរញឹកញាប់ (FREQUENTLY ASKED QUESTIONS, FAQS) បន្ថែមអំពីជំងឺ COVID-19

### ខ្ញុំបានឮដំណឹងនៅលើព័ត៌មានថាមនុស្សមានផ្ទៃពោះអាចនឹងមានហានិភ័យខ្ពស់ទាក់ទងនឹងជំងឺ COVID ។ តើនោះជាការពិតដែរឬទេ?

របាយការណ៍នាពេលថ្មីៗនេះពីមជ្ឈមណ្ឌលត្រួតពិនិត្យនិងបង្ការជំងឺឆ្លង (Centers for Disease Control, CDC) បានរាយការណ៍អំពីការឆ្លងមេរោគ COVID ក្នុងចំណោមស្ត្រីមួយក្រុមធំដែលមានអាយុចន្លោះពី 15 ទៅ 44 ឆ្នាំ។ ការសិក្សាមិនបានរកឃើញការកើនហានិភ័យនៃការកើតជំងឺ COVID-19 ចំពោះស្ត្រីដែលមានផ្ទៃពោះធៀបនឹងស្ត្រីមិនមានផ្ទៃពោះទេ ប៉ុន្តែមានការបង្ហាញថាមានអត្រាឆ្លងខុសគ្នានៃជំងឺ COVID ក្នុងចំណោមស្ត្រីដែលចាត់ទុកខ្លួនឯងថាជាមនុស្សស្បែកខ្មៅ និងអេស្ប៉ាញ។

### តើស្ត្រីមានផ្ទៃពោះមានលទ្ធផលអាក្រក់កាន់តែច្រើនឬទេ ប្រសិនបើពួកគេឆ្លងជំងឺ COVID-19 បើធៀបនឹងស្ត្រីមិនមានផ្ទៃពោះ?

នៅក្នុងរបាយការណ៍ លទ្ធផលខ្លះបង្ហាញអំពីអត្រាខ្ពស់នៃការចូលទៅព្យាបាលនៅមន្ទីរពេទ្យក្នុងចំណោមស្ត្រីមានផ្ទៃពោះ និងកើនច្រើននូវការឆ្លងជំងឺ COVID-19 ព្រមទាំងហានិភ័យកាន់តែច្រើននៃការចូលទីបន្ទប់សង្គ្រោះបន្ទាន់ (Intensive Care Unit, ICU) ហើយត្រូវពាក់ឧបករណ៍ដកដង្ហើម (ជួយដល់ការដកដង្ហើម) បើធៀបនឹងស្ត្រីដែលមិនមានផ្ទៃពោះ។ ចំណុចខ្វះខាតមួយនៃការសិក្សាគឺថា ទោះការចូលទៅសម្រាកនៅមន្ទីរពេទ្យកើនឡើងយ៉ាងច្រើនក្នុងចំណោមស្ត្រីមានផ្ទៃពោះ ច្រើនជាងស្ត្រីមិនមានផ្ទៃពោះក៏ដោយ ក៏ការសិក្សាមិនបានបញ្ចូលព័ត៌មានថាតើការចូលសម្រាកនៅមន្ទីរពេទ្យទាំងនោះគឺពាក់ព័ន្ធនឹងការឆ្លងជំងឺ COVID-19 ឬដោយសារការមានផ្ទៃពោះឬទេ។ លើសពីនេះ លទ្ធផលទាំងនោះអាចនឹងពាក់ព័ន្ធទៅនឹងដែនកំណត់ទាបសម្រាប់ការទទួលយកអ្នកជំងឺមានផ្ទៃពោះ ឬសម្រាប់គោលការណ៍ស្តីពីការពិនិត្យជំងឺ និងការធ្វើតេស្តជាសាកល ដែលមន្ទីរពេទ្យខ្លះបានអនុវត្តសម្រាប់ស្ត្រីដែលត្រូវបានទទួលឲ្យចូលមកមន្ទីរពេទ្យដោយសារការឈឺពោះ និងការសម្រាលកូន។ មិនមានការកើនហានិភ័យចំពោះការស្លាប់ក្នុងចំណោមស្ត្រីមានផ្ទៃពោះ និងមានជំងឺ COVID ទេ បើធៀបនឹងស្ត្រីដែលមិនមានផ្ទៃពោះនិងដែលមានជំងឺ COVID។

## ប្រសិនបើខ្ញុំមានផ្ទៃពោះ តើខ្ញុំអាចធ្វើអ្វីបានដើម្បីនៅតែមានសុវត្ថិភាពពីជំងឺ COVID?

ស្ត្រីមានផ្ទៃពោះគួរព្យាយាមឲ្យអស់ពីសមត្ថភាពដើម្បីមិនឲ្យរំលងការណាត់ជួបពិនិត្យផ្ទៃពោះ។ Atrius Health ស្នើ និងលើកទឹកចិត្តធ្វើការណាត់ជួបពិនិត្យផ្ទៃពោះតាមអ៊ីនធឺណិតនៅពេលមានគ្លីនិកបម្រុងទុក។ ដូចបានអនុវត្តចំពោះប្រជាជនទូទៅដែរ ស្ត្រីមានផ្ទៃពោះគួរកាត់បន្ថយអន្តរសកម្មជាមួយអ្នកដទៃទៀតឱ្យបានច្រើនតាមដែលអាចធ្វើបាន ការប្រុងប្រយ័ត្នដើម្បីបង្ការនឹងជំងឺ COVID-19 នៅពេលទំនាក់ទំនងជាមួយអ្នកផ្សេងទៀត រួមទាំងជៀសវាងការប៉ះពាល់ជាមួយមនុស្សដែលអាចនឹងឈឺ ព្យាយាមពាក់ម៉ាស និងរក្សាគម្លាត ការនៅដាច់ដោយឡែកពីមនុស្សដទៃទៀតនៅពេលចេញក្រៅ និងអនុវត្តអនាម័យដៃឱ្យបានល្អ។ កុំស្ទាក់ស្ទើចំពោះការចែករំលែកជាមួយអ្នកផ្តល់សេវាព្យាបាលរបស់អ្នក ប្រសិនបើមានអ្វីដែលធ្វើឱ្យវាពិបាកសម្រាប់សុវត្ថិភាពអ្នក។

## តើជំងឺ COVID-19 ជាអ្វី?

ជំងឺ COVID-19 គឺជាជំងឺផ្លូវដង្ហើមមួយដែលអាចរាលដាលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ហើយបានរាលដាលទូទាំងសាកលលោកកាលពីប៉ុន្មានខែមុន។ ទោះបីជាមានវីរុសកូរ៉ូណាឆ្លងលើមនុស្សច្រើនប្រភេទ រួមទាំងប្រភេទវីរុសដែលបណ្តាលឲ្យមានជំងឺផ្លូវដង្ហើមផ្នែកខាងលើក៏ដោយ ក៏ជំងឺ COVID-19 កើតឡើងដោយវីរុសកូរ៉ូណាប្រភេទថ្មី ដែលមិនបានរកឃើញនៅក្នុងខ្លួនមនុស្សពីមុនទេ កាលពីមុនខែធ្នូ ឆ្នាំ 2019។

## តើជំងឺ COVID-19 មានរោគសញ្ញាដូចម្តេចខ្លះ ហើយមានអ្វីកើតឡើងប្រសិនបើខ្ញុំបានមានជំងឺនេះ?

មនុស្សភាគច្រើនដែលកើតពីជំងឺ COVID-19 មានអាការៈស្រដៀងគ្នាទៅទៅនឹងជំងឺគ្រុនផ្តាសាយ ក្អក និងថប់ដង្ហើម។ ប្រសិនបើអ្នកចង់ពិនិត្យរោគសញ្ញាតាមអ៊ីនធឺណិត អ្នកប្រើប្រាស់ MyHealth Online អ្នកប្រើប្រាស់អាចចូល និងប្រើកម្មវិធីត្រួតពិនិត្យរោគសញ្ញាជំងឺ COVID-19 របស់ពួកយើងបាន។ គ្រាន់តែចុចលើ ‘Symptom Checker’ និងឆ្លើយសំណួរ។ អាស្រ័យលើរោគសញ្ញាបច្ចុប្បន្ន និងប្រវត្តជំងឺរបស់អ្នក កម្មវិធីអាចនឹងដឹកនាំអ្នកឲ្យបន្តត្រួតពិនិត្យរោគសញ្ញារបស់អ្នកនៅផ្ទះ ទូរសព្ទទៅក្រុមជំនួយផ្នែក COVID ឬណាត់ពេលដើម្បីពិនិត្យមើលតាមវីដេអូដោយបុគ្គលិកគ្លីនិក សម្រាប់វាយតម្លៃបន្ថែម។ ប្រសិនបើអ្នកមិនទាន់ចុះឈ្មោះទៅក្នុង MyHealth ទេ អ្នកក៏អាចសាកល្បង កម្មវិធីពិនិត្យរោគសញ្ញាជំងឺ COVID-19 ពី Buoy Health នេះ។ វាក៏នឹងជួយអ្នកវាយតម្លៃលើហានិភ័យនិងរោគសញ្ញារបស់អ្នក។

CDC ជឿជាក់ថា នៅពេលនោះ រោគសញ្ញារបស់វីរុសកូរ៉ូណាថ្មីនោះ អាចនឹងបង្ហាញចាប់ពីពីរឬបីថ្ងៃ ឬយូររហូតដល់ 14 ថ្ងៃក្រោយពេលប៉ះពាល់។ ដោយមានការសម្រាក និងការគាំទ្រនៅផ្ទះ (ដូចជាការញ៉ាំទឹកឲ្យច្រើន ញ៉ាំ acetaminophen ឬ Tylenol តាមការណែនាំ ជាដើម) មនុស្សភាគច្រើនធូរស្បើយឡើងវិញក្នុងរយៈពេលប៉ុន្មានថ្ងៃរហូតដល់ 1-2 សប្តាហ៍។ បន្តទាក់ទងជាមួយការិយាល័យអ្នកផ្តល់ការថែទាំបឋមរបស់អ្នក សម្រាប់យោបល់គាំទ្រជាក់លាក់សម្រាប់អ្នក។

មនុស្សខ្លះមានហានិភ័យខ្ពស់ដោយមានរោគសញ្ញាកាន់តែធ្ងន់ធ្ងរដោយការឆ្លងជំងឺ COVID-19 ៖ មនុស្សដែលមានជំងឺសួត ឬជំងឺបេះដូង អ្នកជក់បារី អ្នកដែលមានប្រព័ន្ធភាពស៊ាំខ្សោយ ដោយការជំងឺ ឬដោយសារការលេបថ្នាំ និងមនុស្សដែលមានអាយុលើសពី 65 ឆ្នាំ។ ដោយហេតុថា មនុស្សដែលមានស្ថានភាពទាំងនេះអាចមានរោគសញ្ញាកាន់តែធ្ងន់ធ្ងរ វាជាការសំខាន់សម្រាប់ពួកគេដែលត្រូវតាមដានខ្លួនឯងឲ្យបានជិតដល់នៅពេលមានរោគសញ្ញាស្រដៀងផ្តាសាយភ្លាម ហើយត្រូវទាក់ទងការិយាល័យវេជ្ជបណ្ឌិតរបស់ពួកគេដើម្បីមានវិធីល្អបំផុតក្នុងការវាយតម្លៃ ទោះជារោគសញ្ញាគឺស្រាលក៏ដោយ។

## តើជំងឺ COVID-19 ឆ្លងតាមរបៀបណា?

អាស្រ័យលើវិទ្យាសាស្ត្រដ៏ល្អបំផុតរហូតមកដល់បច្ចុប្បន្នេះ គេជឿថា COVID-19 ឆ្លងតាមដំណក់ទឹកពីផ្លូវដង្ហើម ដែលចេញមកក្រៅតាមការក្អក ឬកណ្តាស។ ដោយហេតុថា វីរុសអាចរស់នៅក្នុងដំណក់ទឹកដែលខ្ទាតមកលើផ្ទៃតុ ទូរសព្ទ ឬបង្កាន់ដៃ យើងអាចឆ្លងវីរុសនោះដោយការប៉ះវានឹងមាត់ ច្រមុះ ឬភ្នែក

ក្រោយពេលប៉ះពាល់ដំណក់ទឹកទាំងនោះ។ ដូច្នេះ វាជាការសំខាន់ណាស់ដែលត្រូវ លាងដៃរបស់យើង ឲ្យបានញឹកញាប់ និងសព្វល្អយ៉ាងហោចណាស់ 20 វិនាទី។  ទន្ទឹមនេះ មានហានិភ័យនៃការឆ្លង COVID-19 តាមរយៈភាគល្អិតដែលរសាត់ក្នុងខ្យល់នៅក្នុងស្ថានភាពខ្លះ ដែលកើតឡើងនៅកន្លែងជិតគ្នា រួមទាំងសកម្មភាពដែលបង្កើតឲ្យមានការរសាត់នោះ។

ការរក្សាគម្លាតសុវត្ថិភាព គឺជាវិធីល្អសម្រាប់ពេលនេះ ហើយវាមានន័យថា រក្សាចម្ងាយសុវត្ថិភាពពីគ្នា ដើម្បីព្យាយាមកាត់បន្ថយឱកាសចម្លងជំងឺគ្នាទៅមក ប្រសិនបើអ្នកឆ្លង COVID-19។ ជាទូទៅ ការនៅឆ្ងាយពីគ្នាចម្ងាយ 6 ហ្វីតគឺចាត់ទុកជាចម្ងាយសុវត្ថិភាព។ លើសពីនេះ លោកអភិបាល Baker បានចេញបទបញ្ជីដែលចាប់ផ្តើមមានប្រសិទ្ធភាពកាលពីថ្ងៃពុធទី 6 ខែឧសភា ឆ្នាំ 2020 ដែលតម្រូវឲ្យពាក់ម៉ាស ឬក្រណាត់បាំងមុខនៅទីសាធារណៈ ប្រសិនបើមិនអាចរក្សាគម្លាតបាន។

តើធ្វើដូចម្តេចដើម្បីបង្ការការរីករាលដាលនៃវីរុសកូរ៉ូណា**?**

អនាម័យដៃជាប្រចាំ និងសុជីវធម៌ក្នុងការក្អក គឺជាវិធីល្អបំផុតដើម្បីបង្ការការរីករាលដាលនៃវីរុសសួតដូចជា COVID-19។ អ្នកគួរអនុវត្តដូចខាងក្រោម៖

- លាងសម្អាតដៃរបស់អ្នកជាញឹកញាប់ដោយទឹកនិងសាប៊ូ យ៉ាងហោចណាស់ **20** វិនាទី ជាពិសេស ក្រោយពីប្រើបង្គន់ មុនពេលបរិភោគ និងក្រោយពេលញើសសំបោរ ក្អក ឬកណ្តាស។
- ពាក់ក្រណាត់បាំងមុខ ឬម៉ាស
- នៅពេលក្អក ឬកណ្តាស ត្រូវខ្ទប់ច្រមុះ និងមាត់ដោយប្រើគន្លាក់ដៃ ឬក្រដាស់ជូតមាត់។ លាងដៃរបស់អ្នករាល់ពេល។
- ជៀសវាងការប៉ះភ្នែក ច្រមុះ និងមាត់។
- ជៀសវាងការប៉ះពាល់អ្នកដែលឈឺ
- នៅផ្ទះប្រសិនបើអ្នកឈឺ លើកលែងតែចេញទៅព្យាបាលចាំបាច់

តើនរណាខ្លះដែលគួរធ្វើតេស្តរកជំងឺ **COVID-19?**

នៅពេលនេះ ការធ្វើតេស្តគួរធ្វើឡើងសម្រាប់អ្នកជំងឺទាំងអស់ ដែលមានរោគសញ្ញាជំងឺ **COVID-19** (ក្តៅខ្លួន ក្អក តឹងច្រមុះ ដង្ហើមលីស្ងួរង៉ឺតៗ ឈឺបំពង់ក និងឬដង្ហក់) ព្រមទាំងរោគសញ្ញាផ្សេងទៀត ចំពោះមនុស្សដូចខាងក្រោម រួមទាំងអ្នកជំងឺដែលបានពាក់ព័ន្ធនឹង COVID-19៖

- អ្នកជំងឺមានផ្ទៃពោះដែលគ្រោងសម្រាលកូនដោយការវះ ឬបូម ដែលមិនអាចទៅធ្វើតេស្តជាមុនបាន នៅពេលទៅមន្ទីរពេទ្យដើម្បីសម្រាល
- អ្នកជំងឺដែលរស់នៅ ឬធ្វើការនៅកន្លែងចង្អៀត ដែលមានភស្តុតាងថាផ្ទុះជំងឺ (ឧ. កន្លែងថែទាំនៅតាមផ្ទះ កន្លែងថែទាំជំនាញ កន្លែងស្នាក់នៅសម្រាប់អ្នកគ្មានទីជម្រក ផ្ទះរស់នៅជាក្រុម) ឬអ្នកដែលត្រូវបានបញ្ជូនដោយនាយកដ្ឋានសុខភាពសាធារណៈ ឬកន្លែងស្នាក់នៅសម្រាប់ការធ្វើតេស្តជាផ្នែកមួយនៃការស៊ើបអង្កេត
- អ្នកជំងឺដែលត្រូវធ្វើតេស្តជាផ្នែកមួយនៃលក្ខណវិនិច្ឆ័យនៃការវិលត្រលប់មកធ្វើការវិញ
- អ្នកជំងឺដែលគ្រោងមាន ឬអនុវត្តទម្រង់ការដែលបង្កើតការសាយខ្យល់ ឬផ្លូវដង្ហើម ដូចជាការវះកាត់ចុះពោះវៀន ត្រចៀក ច្រមុះ និងបំពង់ក (Ear, Nose & Throat, ENT) និងការធ្វើធ្មេញ។
- អ្នកជំងឺដែលបានពាក់ព័ន្ធនឹងជំងឺ COVID-19 និងបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖
    - បានទទួលសារជាអក្សរ ឬលិខិតពីក្រុមការងារ Massachusetts COVID Team ឬក្រុមប្រឹក្សាសុខភាពមូលដ្ឋានដែលជូនដំណឹងដល់ពួកគេថាពួកគេត្រូវបានកំណត់អត្តសញ្ញាណថាបានពាក់ព័ន្ធនឹងករណី COVID-19 ។

- ជឿថាត្រូវបានពាក់ព័ន្ធនឹង COVID-19 តាមរយៈសមាជិកគ្រួសារ (ដូចជា កូន ឪពុកម្តាយ បងប្អូនដែលត្រូវបានធ្វើរោគវិនិច្ឆ័យថាមានជំងឺ COVID-19 នៅក្នុងគ្រួសារ)។
- បានប៉ះពាល់ជាមួយមនុស្សដែលត្រូវបានបញ្ជាក់ថាមានជំងឺ COVID-19 (កន្លែងធ្វើការ ឬពាក់ព័ន្ធនៅសហគមន៍) និងស្ថិតនៅចម្ងាយតិចជាង 6 ហ្វីតពីបុគ្គលនោះជាបន្តបន្ទាប់រយៈពេលចាប់ពី 15 នាទីឡើងដោយមិនមានពាក់ឧបករណ៍ការពារខ្លួន។
- ប្រសិនបើចាំបាច់ត្រូវទៅមើលអ្នករស់នៅកន្លែងថែទាំរយៈពេលវែង ការចូលរួមថែទាំនៅពេលថ្ងៃ ឬបោះជំរុំនៅរដូវក្តៅ ឬធ្វើដំណើរទៅគោលដៅ នោះលទ្ធផលតេស្តអាចនឹងមានឥទ្ធិពលមកលើលក្ខខណ្ឌតម្រូវនៃចត្តាឡីស័ក។

**តើគេធ្វើតេស្តរកជំងឺ COVID-19 តាមរបៀបណា?**

តេស្តរកជំងឺ COVID-19 តម្រូវឲ្យមានការត្បារដោយសំឡីចូលក្នុងរន្ធច្រមុះដើម្បីផ្តិតយករំអិលនៅផ្នែកក្នុងជ្រៅនៃច្រមុះដើម្បីធ្វើសំណាក។ អ្នកយកសំណាកពីអ្នកនឹងពាក់ឧបករណ៍ការពារខ្លួនដូចជា របាំងមុខ ម៉ាសអាវបំពង់ និងស្រោមដៃ។

**តើខ្ញុំគួរទៅធ្វើតេស្តឬទេ ប្រសិនបើខ្ញុំបានប៉ះពាល់មនុស្សដែលមានតេស្តវិជ្ជមានសម្រាប់ជំងឺ COVID-19?**

គួរ។ ប្រសិនបើនរណាម្នាក់បានទៅនៅជិតនរណាម្នាក់ដែលមានជំងឺ COVID-19 អ្នកគួរធ្វើតេស្ត។ ទោះយ៉ាងណា ប្រសិនបើអ្នកបានចាក់វ៉ាក់សាំងពេញលេញហើយ ហើយបានពាក់ព័ន្ធនឹងជំងឺ COVID-19 អ្នកមិនចាំបាច់នៅឲ្យឆ្ងាយពីមនុស្ស ឬទៅធ្វើតេស្តទៀតទេ លុះត្រាតែអ្នកមានរោគសញ្ញា។

**តើខ្ញុំគួរធ្វើដូចម្តេច ប្រសិនបើខ្ញុំមានជំងឺ COVID-19?**

CDC មានព័ត៌មានច្រើនអំពី អ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកឈឺ និង របៀបថែទាំខ្លួនឯងនៅផ្ទះ។ ហើយសូមកុំស្ទាក់ស្ទើរនឹងទាក់ទងមកអ្នកផ្តល់ការថែទាំនៅ Atrius Health ប្រសិនបើអ្នកព្រួយបារម្ភអំពីអាការៈដែលកាន់តែអាក្រក់។

**តើពេលណាទើបខ្ញុំដឹងថាខ្ញុំជាសះស្បើយពី COVID-19?**

CDC និយាយថា អ្នកបានជាសះស្បើយហើយ ប្រសិនបើវាកន្លងហួសយ៉ាងតិច 10 ពីថ្ងៃចេញរោគសញ្ញាដំបូង ប្រសិនបើអ្នកលែងក្តៅខ្លួន 24 ម៉ោង និងមិនប្រើថ្នាំបញ្ចុះកម្តៅ ហើយរោគសញ្ញារបស់អ្នកបានធូរស្បើយយ៉ាងច្រើន។

**តើខ្ញុំត្រូវនិយាយដូចម្តេចទៅកូនៗរបស់ខ្ញុំអំពី COVID-19?**

យើងយល់ថា អ្វីដែលកំពុងកើតឡើងនៅពេលនេះ គឺពិបាកខ្លាំងណាស់សម្រាប់មនុស្សពេញវ័យដោះស្រាយ ហើយវាក៏ច្របូកច្របល់ និងគួរឲ្យខ្លាចយ៉ាងខ្លាំងសម្រាប់កុមារផងដែរ។ CDC មានទំព័រទាំងមូលនៅលើគេហទំព័ររបស់គេ ទុកសម្រាប់ជួយដល់ឪពុកម្តាយនិងអាណាព្យាបាលសម្រាប់និយាយជាមួយកូនៗអំពី COVID-19 តាំងពីគោលការណ៍ទូទៅដែលត្រូវប្រើប្រាស់នៅពេលចាប់ផ្តើម និងបន្តការសន្ទនា រហូតដល់របៀបឆ្លើយសំណួរងាយយល់សម្រាប់កុមារអំពី COVID-19។